- សហការ សម្របសម្រួល ផ្តួចផ្តើម និងស្រាវជ្រាវពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- ពិនិត្យ សិក្សា លើកសំណើ និងផ្តល់យោបល់លើការស្រាវជ្រាវពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល

- រៀបចំរបាយការណ៍ស្រាវជ្រាវពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផល បញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានស្រាវជ្រាវ គោល-នយោបាយ និងច្បាប់។

**ប្រការ៧.-**

ការិយាល័យគោលនយោបាយនិងច្បាប់ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានស្រាវជ្រាវ គោល-នយោបាយ និងច្បាប់ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ សិក្សា ស្រាវជ្រាវ និងសម្របសម្រួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ពិនិត្យ សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់លើការរៀបចំ ការកែសម្រួល ការធ្វើទំនើបកម្ម និង/ឬការធ្វើសុវត្ថិកម្មគោលនយោបាយ និងយុទ្ធសាស្ត្រ ពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋ-កិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ចូលរួមរៀបចំ កែសម្រួល និង/ឬធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រម-ព្រៀង និងលិខិតគតិយុត្ត ពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ចូលរួមរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការពាក់ព័ន្ធការកសាង ការកែសម្រួល និង/ឬការធ្វើវិសោធនកម្មច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យា ឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- រៀបចំ ប្រមូល ចងក្រង និងនិពន្ធស្នាដៃនីតិសាស្ត្រ ឬគតិយុត្តជាអាទិ៍កម្រងសម្រង់ មគ្គុទេសក៍ ព្រឹត្តិបត្រ ទស្សនាវដ្តី និងឯកសារគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល សម្រាប់រយៈពេលខ្លី មធ្យម និងវែង
- សហការ និងសម្របសម្រួលការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- វិភាគពីគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ផ្តួចផ្តើមគំនិតរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ពិនិត្យ សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់លើគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផល បញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានស្រាវជ្រាវ គោល-នយោបាយ និងច្បាប់។

## ផ្នែកទី៣
## តួនាទីនិងភារកិច្ចរបស់ការិយាល័យចំណុះឱ្យ
## នាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ

**ប្រការ៨.-**

ការិយាល័យគម្រោងនិងកម្មវិធីអភិវឌ្ឍ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំគម្រោងនិងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- សហការ និងសម្របសម្រួលការរៀបចំគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- វិភាគជាអាទិ៍ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព សក្តានុពល និងការគំរាមកំហែង ហានិភ័យ ឬបញ្ហាប្រឈមនៃគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ផ្តួចផ្តើមគំនិតរៀបចំគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ពិនិត្យ សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់លើការរៀបចំគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ជំរុញការរៀបចំ ការអនុវត្ត និងការអភិវឌ្ឍគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- គ្រប់គ្រងគម្រោង និងកម្មវិធីអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផល បញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ។

**ប្រការ៩.-**

ការិយាល័យនវានុវត្តន៍ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- កសាង និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាឌីជីថល នវានុវត្តន៍ និងថ្នាលឌីជីថលគន្លឹះ សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- ស្រាវជ្រាវបែបអនុវត្តន៍ដើម្បីស្វែងរកនវានុវត្តន៍ក្នុងការធ្វើសុវត្ថិកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងថ្នាលឌីជីថលគន្លឹះ បម្រើដល់ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល

- សហការជាមួយនឹងបណ្ដាសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវជាតិ និងអន្តរជាតិ ដើម្បីជំរុញនវានុវត្តន៍ក្នុងការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- សិក្សា និងស្រាវជ្រាវបច្ចេកវិទ្យាឌីជីថលថ្មីៗ ព្រមទាំងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងថ្នាលឌីជីថលគន្លឹះជាប្រចាំ ដើម្បីធានាបាននូវសុវត្ថិភាព និងគុណភាពនៃប្រព័ន្ធទាំងមូល
- ផ្តល់ប្រឹក្សាបច្ចេកទេសដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល និងថ្នាលឌីជីថលគន្លឹះ
- ចងក្រងឯកសារបច្ចេកទេសស្តីពីការរៀបចំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងថ្នាលឌីជីថលគន្លឹះ រួមទាំងសេចក្តីណែនាំពាក់ព័ន្ធការធ្វើសមាហរណកម្មរវាងប្រព័ន្ធ និងប្រព័ន្ធ
- ចូលរួមកសាងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា និងប្រព័ន្ធអេកូឡូស៊ីឌីជីថល តាមរយៈការធ្វើសន្ទានកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងការបើកចំហទិន្នន័យតាមសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ
- ចូលរួមកសាង និងគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ ដោយធានាបាននូវប្រតិបត្តិការ និងសុវត្ថិភាពប្រព័ន្ធទាំងមូលជាអតិបរមា
- គ្រប់គ្រង ប្រតិបត្តិ និងថែទាំប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងថ្នាលឌីជីថលគន្លឹះ ដែលបានអភិវឌ្ឍដោយអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** និងតាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- កៀរគរធនធានមនុស្សផ្នែកនវានុវត្តន៍ជាគុណប្រយោជន៍ដល់ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផល បញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានគម្រោង នវានុវត្តន៍ និងកម្មវិធីអភិវឌ្ឍ។

## ផ្នែកទី៤

## តួនាទីនិងភារកិច្ចរបស់ការិយាល័យចំណុះឱ្យ នាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ

**ប្រការ១០.-**

ការិយាល័យបណ្តុះបណ្តាល បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- សហការ និងសម្របសម្រួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាលពាក់ព័ន្ធ តាមការសម្រេចរបស់ **គ.ស.ធ.ឌ.**
- ជំរុញការរៀបចំ ការអនុវត្ត និងការអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាលពាក់ព័ន្ធ

- ពិនិត្យ សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់លើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាលពាក់ព័ន្ធ
- ចែករំលែកបទពិសោធ សមត្ថភាព ជំនាញវិជ្ជាជីវៈ ទិន្នន័យ និងឧត្តមានុវត្តន៍នៃការបណ្តុះបណ្តាលពាក់ព័ន្ធជូនក្រសួង-ស្ថាប័ន
- បណ្តុះបណ្តាលពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលគន្លឹះ ដែលបានអភិវឌ្ឍដោយអគ្គលេខាធិការដ្ឋាន **គ.ស.ឌ.ឌ.**
- អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាលពាក់ព័ន្ធ
- គ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការបណ្តុះបណ្តាលពាក់ព័ន្ធ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលបញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានបណ្តុះបណ្តាលផ្សព្វផ្សាយ និងសហប្រតិបត្តិការ។

**ប្រការ១១.-**

ការិយាល័យផ្សព្វផ្សាយនិងសហប្រតិបត្តិការ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានបណ្តុះ-បណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការផ្សព្វផ្សាយ និងសហប្រតិបត្តិការ សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ប្រកបដោយសហថាមភាព សហនវានុវត្តន៍ និងសិនិទ្ធភាព
- សហការ និងសម្របសម្រួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការផ្សព្វផ្សាយ និងសហប្រតិបត្តិការពាក់ព័ន្ធ តាមការសម្រេចរបស់ **គ.ស.ឌ.ឌ.**
- ពិនិត្យ សិក្សា ស្រាវជ្រាវ លើកសំណើ និងផ្តល់យោបល់លើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការផ្សព្វផ្សាយ និងសហប្រតិបត្តិការពាក់ព័ន្ធ
- ជំរុញការរៀបចំ ការអនុវត្ត និងការអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី និងផែនការផ្សព្វផ្សាយ និងសហប្រតិបត្តិការពាក់ព័ន្ធ
- រៀបចំនិងគ្រប់គ្រងថ្នាលឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយ សំដៅដល់ការផ្តល់ទិន្នន័យ និងព័ត៌មានគ្រប់ជ្រុងជ្រោយពាក់ព័ន្ធសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- ចូលរួមសហការរៀបចំកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា
- បំពេញតួនាទីជាកន្លែងផ្តល់ព័ត៌មានពាក់ព័ន្ធការងារ សកម្មភាព និងសមិទ្ធកម្មរបស់ **គ.ស.ឌ.ឌ.**

- ធ្វើកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេសជាមួយនឹងដៃគូពាក់ព័ន្ធសំខាន់ៗក្នុងវិស័យសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសដើម្បីទាញយកបទពិសោធ និងប្រមូលធាតុចូល សំដៅកសាង និងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលបញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ។

## ផ្នែកទី៥
## តួនាទីនិងភារកិច្ចរបស់ការិយាល័យចំណុះឱ្យ នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ១២.-**

ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំយន្តការ ប្រព័ន្ធ គោលការណ៍ វិធាន នីតិវិធី វិធីសាស្ត្រ ស្តង់ដារ និងផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យា ឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- កំណត់សូចនាករសមិទ្ធកម្មគន្លឹះ និងទិន្នន័យជាមូលដ្ឋានសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល រយៈពេលខ្លី មធ្យម និងវែង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល
- លើកសំណើកែសម្រួលវិធានការគោលនយោបាយ និងគតិយុត្តតាមការចាំបាច់ និងរៀបចំរបាយការណ៍ជូននាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ពិនិត្យ សម្រេច និងចាត់វិធានការបន្ត
- លើកសំណើធ្វើសុវត្ថិកម្មការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល

- ចងក្រង និងវិភាគទិន្នន័យគោលនយោបាយ និងគតិយុត្តសម្រាប់ធ្វើរបាយការណ៍ និងការសម្រេចចិត្តផ្នែកគោលនយោបាយ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលបញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**ប្រការ១៣.-**

ការិយាល័យផែនការ សរុប និងស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ចូលរួមរៀបចំ ធ្វើបច្ចុប្បន្នកម្ម សហការ និងសម្របសម្រួលផែនការកសាងនិងអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ជាមួយនឹងការិយាល័យជំនាញផ្សេងទៀត
- បូកសរុបទិន្នន័យ ស្ថិតិ និងរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ទិសដៅ កម្មវិធី គម្រោង និងផែនការ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចសន្យាឬកិច្ចព្រមព្រៀង និងលិខិតគតិយុត្តផ្សេងទៀត ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និងសង្គមឌីជីថល ដោយសហការនិងសម្របសម្រួលជាមួយនឹងការិយាល័យជំនាញផ្សេងទៀត
- ចូលរួមក្នុងកិច្ចប្រជុំ និង/ឬសិក្ខាសាលា និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំ និងបូកសរុបកំណត់បង្ហាញ ជំនួយស្មារតី លទ្ធផល និង/ឬកំណត់ហេតុនៃកិច្ចប្រជុំ និង/ឬសិក្ខាសាលា និងបូកសរុបរបាយការណ៍កិច្ចប្រជុំរបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** និង **គ.ស.ធ.ឌ.** ដោយសហការនិងសម្របសម្រួលជាមួយនឹងការិយាល័យជំនាញផ្សេងទៀត
- ផ្សព្វផ្សាយរបាយការណ៍កិច្ចប្រជុំ និងសេចក្តីសម្រេចរបស់ **គ.ស.ធ.ឌ.**
- សហការ សម្របសម្រួល និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ របស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.**
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ឬប្រសិទ្ធផលបញ្ហាប្រឈម និងរបាយការណ៍ប្រជុំរបស់ការិយាល័យប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាននាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦រោច ខែបុស្ស ឆ្នាំឆ្លូវ ចត្វាស័ក ព.ស.២៥៦៥

ធ្វើរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃប្រកាសលេខ** ៤៣៩ **ចុះថ្ងៃទី**២៦ **ខែ** ... **ឆ្នាំ**២០២២

**ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** (គ.ស.ធ.ឌ.)

**អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ.**



**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០៥៦ ..............សហវ-ប្រក

ថ្ងៃព្រហ ៤រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២២

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៧៨៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តព្រះវិហារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ខេត្តព្រះវិហារ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ប្រាក់ សុខណ្ណា** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក **យ៉ុខ គីមហ៊ាន** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក **អាន សុទ្ធី** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. | លោក **សំ សារឿន** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៥. | លោក **យ៉ុខ គីមហឿង** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦. | លោក **ម៉ុម សុទ្ធារ៉ា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៧. | លោក **ពីខ ទ្រីដា** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៨. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | សមាជិក |
| ៩. | លោក **សុខ សុគន្ធរ័ត្ន** | អនុប្រធានប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១០. | លោក **ម៉ុល បូរិន** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១១. | លោក **សុខ ប៊ុន្នី** | ប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១២. | **ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ស្រុក** | | សមាជិក |
| ១៣. | លោកស្រី **សំ សុជាតិ** | អនុប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១៤. | **លោក លោកស្រី មេឃុំ ចៅសង្កាត់** | | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ច ដូចខាងក្រោម ÷

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធ ដាក់ជូនគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ។

**ប្រការ ៤.-**

សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៥.-**

អនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**ប្រការ ៦.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់**

**បណ្ឌិតសភាចារ្យ វង្សី វិស្សុត**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៥៨២ រថ.អប្រក.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
# លេខ ០៥៨២ រថ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់លោក ឌិន វណ្ណា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ ដេប៉ូតេលា វណ្ណា ចំរើន ស្ថិតនៅភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី របស់លោក ឌិន វណ្ណា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យតាំងលក់ឥវ៉ាន់ ដោយគ្មានសណ្តាប់ធ្នាប់ក្នុងទីធ្លាស្ថានីយ ប៉ុន្តែម្ចាស់ស្ថានីយអាចដាក់លក់បាននៅទីតាំងដែលមានការរៀបចំបានត្រឹមត្រូវ នៅឆ្ងាយពីបម្រិតណ្ឌស្ថានីយ

២. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ

៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវរៀបចំឱ្យសមស្របតាមសារាចរ

៤. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីព្រំដីស្ថានីយ ក្នុងទីលម្ហ

៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៦. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

៧. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

៨. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៤៨៧.រថ:អប៉ក.លអ........ចុះថ្ងៃទី....០៣.............ខែ...មិថុនា......ឆ្នាំ២០២១................របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៤៨៧.រថ:អប៉ក.លអ ចុះថ្ងៃទី......០៣.....ខែ....មិថុនា.......ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តមណ្ឌលគិរី និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍..៨រោច.ខែ.ជេស្ឋ......ឆ្នាំឆ្លូវ..ត្រីស័ក ព.ស.២៥៦៥.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៣.ខែ...មិថុនា.ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តមណ្ឌលគិរី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤៨៦ រ.ថ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០៤៨៦ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ សូគីម៉ិច ឡាប៉េ ស្ថិតនៅភូមិមណ្ឌល១ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប របស់ ក្រុមហ៊ុន សុខ គង់ អាហារ៍ណ នីហារ៍ណ (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគាររបស់ស្ថានីយ
២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីព្រំដីស្ថានីយក្នុងទីជុំ
៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគារលក់ប៊ីប៉ុរ

៤. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ
៥. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយ និងគួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ
៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៧. ត្រូវបិទស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៩. ត្រូវរៀបចំផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៦៨៦.រ៉េ.អប្រក.លអ..........ចុះថ្ងៃទី.....១១.............ខែ..មិថុនា......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៦៨៦.រ៉េ.អប្រក.លអ ចុះថ្ងៃទី.....១១.......ខែ......មិថុនា.....ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តសៀមរាប និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ...២កើត....ខែ..បឋមាសាឍឆ្នាំឆ្លូវ...ត្រីស័ក.ព.ស.២៥៦៥.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១១...ខែ..មិថុនា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤៩១ រ៨.អប.ប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០៤៩១ រ៨.អប.ប្រក.ពអ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយចម្រុះប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ ក្រុមហ៊ុន សូគីម៉ិច ស្ទឹងមានជ័យ ស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ របស់ ក្រុមហ៊ុន សុខ គង់ អាហារ៍ណា នីហារ៍ណា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធររាជធានីភ្នំពេញ
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានដាក់លក់ធុងឧស្ម័នឥន្ធនៈនៅក្នុងបរិវេណស្ថានីយ

២. ទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីរបងស្ថានីយ

៣. ពោងប្រេងឥន្ធនៈកប់ដីត្រូវមានចំណុះមិនលើសពី ៣០ ០០០ លីត្រ

៤. គួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ
៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៧. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៨. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៥៩១.១៨.ររ.ប្រក.លរ........ចុះថ្ងៃទី...១៨.............ខែ..មិថុនា......ឆ្នាំ២០២១..............របស់ ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៥៩១..១៨.ររ.ប្រក.លរ ចុះថ្ងៃទី....១៨......ខែ..មិថុនា........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ..៥កើត.....ខែបឋមាសាឍឆ្នាំឆ្លូវ..ត្រីស័ក.ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៨...ខែ.មិថុនា...ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ-សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៥៩៩.រថ.អប្រក.ប្រក

# ប្រកាស
## ស្ដីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ លេខ០៥៩៩.រថ.អប្រក.ពអ...ចុះថ្ងៃទី...១៥.....ខែ..មិថុនា..ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ របស់លោក តាន់ គិរិយា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ ដេប៉ូតេលា តាន់ គិរិយា ស្ថិតនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប របស់លោក តាន់ គិរិយា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ

២. ពោងឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ ម៉ែត្រពីអគារ ហើយត្រូវស្ថិតនៅទីស្រឡះល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា

៣. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៤. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ

៥. ត្រូវរៀបចំកបំពង់ទទួលប្រេងឥន្ធនៈ

៦. កបំពង់ទទួលឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ ម៉ែត្រ ពីអគារ

៧. ត្រូវមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេង និងឧស្ម័នឥន្ធនៈ និងគន្លឹះអាសន្នរួម

៨. ទូចាក់ឧស្ម័នទៅមាត់កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រ

៩. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

១០. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពគ្រប់គ្រាន់

១១. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ

១២. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០**.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១**.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៥៩៩.រជ.អប្រក.ពអរ........ចុះថ្ងៃទី......១៥...........ខែ..មិថុនា......ឆ្នាំ២០២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២**.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៥៩៩.រជ.អប្រក.ពអរ ចុះថ្ងៃទី....១៥......ខែ...មិថុនា.......ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តសៀមរាប និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ..៦កើត..ខែបឋមាសាឍឆ្នាំឆ្លូវ..ត្រីស័កព.ស.២៥៦៥.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.១៥...ខែ.មិថុនា...ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល**:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ០៦០៥.រជ.អប្រក.ប្រក

# ប្រកាស

## ស្តីពី

## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ លេខ០៦០៥.រជ.អប្រក..លអ....ចុះថ្ងៃទី...១៥.....ខែមិថុនា....ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រជ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ របស់លោក ហៀង ភារិន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោឈ្មោះ ដេប៉ូតេលា ភារិន ដារីហ្គាស ស្ថិតនៅភូមិស្វាយជ្រុំ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង របស់លោក ហៀង ភារិន (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ក្បាលដីស្ថានីយគួរមានប្រវែងអប្បបរមា ២៥ ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ
៣. ពោងឧស្ម័នឥន្ធនៈគួរមានចំណុះមិនលើសពី ១០ តោន

៤. ចម្ងាយពីពោងឧស្ម័នឥន្ធនៈលើដីទៅរបងព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ៧,៥ ម៉ែត្រ ហើយត្រូវស្ថិតនៅទីស្រឡះអាចឱ្យខ្យល់បក់ផាត់បានល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា

៥. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៦. ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន

៧. បំពង់ខ្យល់ប្រេងឥន្ធនៈមានបំពាក់វ៉ាន់បិទ បើក

៨. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន

៩. ចម្ងាយពីមាត់កបំពង់ទទួលឧស្ម័នឥន្ធនៈទៅព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ៣ ម៉ែត្រ

១០. ចម្ងាយពីទូចាក់ប្រេងឥន្ធនៈ ទៅទូចាក់ឧស្ម័នឥន្ធនៈត្រូវមានប្រវែងអប្បបរមា ៧ ម៉ែត្រ

១១. ត្រូវរៀបចំកបំពង់ទទួលប្រេងឥន្ធនៈ

១២. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈពីការប៉ះទង្គិច

១៣. ត្រូវមានបំពាក់គន្លឹះអាសន្នរួមមួយក្នុងទីធ្លាស្ថានីយ

១៤. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ

១៥. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តផ្ទេរប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈ

១៦. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

១៧. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីស្តីពីការផ្ទេរប្រេងឥន្ធនៈ និងផ្ទេរឧស្ម័នឥន្ធនៈ

១៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណង អនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និង ថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៦០៤.ទជ.អរ.ប្រក.សស......ចុះថ្ងៃទី.....១៤............ខែ..មិថុនា......ឆ្នាំ២០២១..............របស់ ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៦០៤.ទជ.អរ.ប្រក.សស ចុះថ្ងៃទី....១៤......ខែ..មិថុនា........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបាត់ដំបង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ...៥កើត..ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៤...ខែ.មិថុនា...ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៦១១ រស.អប្រក.ប្រក

# ប្រកាស
## ស្ដីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ ០៦១១ រស.អប្រក.លអ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោ សូគីម៉ិច មុខព្រលាន ស្ថិតនៅភូមិថ្នល់ ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប របស់ ក្រុមហ៊ុន សុខ គង់ អាហារ៍ណ នីហរ៍ណ (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងឧស្ម័នឥន្ធនៈដាក់លើដី គួរមានចំណុះមិនលើសពី ១០ តោន

២. ពោងឧស្ម័នឥន្ធនៈដាក់លើដី ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវស្ថិតនៅទីស្រឡះល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារការប៉ះទង្គិចនានា

៣. ពោងឧស្ម័នឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ ម៉ែត្រពីទូចាក់ឧស្ម័នឥន្ធនៈ
៤. មិនអនុញ្ញាតឱ្យមានបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈដាក់ប៊ីដុងធំរក្នុងទីធ្លាស្ថានីយ
៥. ស្ថានីយប្រេងឥន្ធនៈ ត្រូវមានបរិមាណផ្ទុកប្រេងមិនលើសពី ១៥០ ០០០ លីត្រសម្រាប់លក់ចែកចាយដល់សាធារណៈជន
៦. ពោងប្រេងឥន្ធនៈកប់ដីត្រូវមានចំណុះមិនលើសពី ៣០ ០០០ លីត្រ
៧. ពោងប្រេងឥន្ធនៈគ្រប់ប្រភេទត្រូវកប់ក្រោមដីទាំងអស់
៨. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីព្រំដីស្ថានីយ ក្នុងទីលម្ហ
៩. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ
១០. ទូចាក់ឧស្ម័នឥន្ធនៈទៅរបងព្រំដីស្ថានីយត្រូវមានចម្ងាយអប្បបរមា ៧,៥ ម៉ែត្រ
១១. ត្រូវមានបំពាក់គន្លឹះអាសន្នរួម និងគួរមានគន្លឹះអាសន្នតាមទូចាក់
១២. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១៣. ត្រូវបិទស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១៤. ត្រូវរៀបចំផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១៥. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៥១១.១៦៖អមែក.លអ..........ចុះថ្ងៃទី.......១៥..........ខែ...មិថុនា.....ឆ្នាំ២០១៧...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៥១១.១៦៖អមែក.លអ ចុះថ្ងៃទី......១៥.....ខែ..មិថុនា.........ឆ្នាំ២០១៧....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តសៀមរាប និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ...៦កើត..ខែបឋមាសាឍ.ឆ្នាំរកា...ត្រីស័ក.ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...១៥..ខែ.មិថុនា..ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តសៀមរាប
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៦១២ រ៉ែ.អឯក.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០៦១២ រ៉ែ.អឯក.លអ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បកចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់លោក **សុខ គង់ តំណាងក្រុមហ៊ុន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ យីហោ **សូគីម៉ិច ទន្លេបាសាក់** ស្ថិតនៅផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ របស់ **ក្រុមហ៊ុន សុខ គង់ អាហរ័ណ នីហរ័ណ** (**ម្ចាស់ស្ថានីយ**)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ នូវចំណុចបច្ចេកទេស ដូចខាងក្រោម៖



ឥ ឬ

១. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពី របងព្រំដីស្ថានីយ
២. ត្រូវបំពាក់គន្លឹះរាសន្ទនៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
៣. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ម៉ែត្រ ពី របងព្រំដីស្ថានីយ
៤. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៥. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៦. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៧. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែនិងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៦១៧.រ៉ែ.អ(បក.សអ..........ចុះថ្ងៃទី.....២៣...........ខែ..មិថុនា......ឆ្នាំ២០២១..............របស់ក្រសួងរ៉ែនិងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០៦១៧.រ៉ែ.អ(បក.សអ. ចុះថ្ងៃទី.....២៣....ខែ.....មិថុនា.....ឆ្នាំ២០២១.......នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និង **ក្រុមហ៊ុន សុខ គង់ អាហារ៉ណ នីហារ៉ណ** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ....១៤កើត.....ខែបឋមាសាឍ..ឆ្នាំឆ្លូវ.ត្រីស័ក..ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....២៣......ខែ.មិថុនា.......ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -រដ្ឋបាលរាជធានីភ្នំពេញ
- -ដូចប្រការ១៣
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៦១៩.១៥.ឆស.ប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ ០៦១៩.១៥.ឆស.ប្រក.ឈអ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ សូគីម៉ិច បន្ទាយមានជ័យ ស្ថិតនៅភូមិ១ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ របស់ ក្រុមហ៊ុន សុខ គង់ អាហារ័ណ នីហរ័ណ (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ នៅពេលដំឡើងគ្រឿងបង្ហុំឧស្ម័នឥន្ធនៈរួចរាល់

២. ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន

៣. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគាររបស់ស្ថានីយ
៤. គួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ
៥. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៦. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៧. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៨. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០៦១៩.ទជ.រស.ប្រក.លរស......ចុះថ្ងៃទី.....២៣.........ខែ..មិថុនា.....ឆ្នាំ២០២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៦១៩.ទជ.រស.ប្រក.លរស ចុះថ្ងៃទី...២៣......ខែ.មិថុនា.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ...១៤កើត.ខែបឋមាសាឍឆ្នាំឆ្លូវ.ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៣..ខែ.មិថុនា..ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបន្ទាយមានជ័យ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៦២៣ រ.ជ.អប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
## លេខ ០៦២៣ រ.ជ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យ អន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹង ប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធី នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់លោក សុខ គង់ តំណាងក្រុមហ៊ុន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោឈ្មោះ សូគីម៉ិច ស្ថិតនៅសង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ របស់ ក្រុមហ៊ុន សុខ គង់ អាហារ៍ណា នីហារ៍ណា (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ក្រុមហ៊ុនត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖
- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ក្រុមហ៊ុនត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ត្រូវសង់របងនៅប៉ែកខាងព្រំដីស្ថានីយដែលមានពោងឧស្ម័នឥន្ធនៈដាក់លើដី ដោយបន្ថែមកម្ពស់អប្បបរមា ១,៨ ម៉ែត្រទៀត គិតចាប់ពីផ្ទៃខាងលើរបស់ពោង ដែលរបងនោះធ្វើពីបេតុងអាមេអាចធន់នឹងការផ្ទុះ ឬឆេះក្នុងរយៈពេលយ៉ាងតិចពីរម៉ោង និងត្រូវមានចម្ងាយប្រមាណ

ប្រវែង ៧,៥ ម៉ែត្រពីពោងនោះទៅចុងសងខាងនៃរបងការពារនោះត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា

២. ចម្ងាយពីពោងឧស្ម័នឥន្ធនៈទៅទូចាក់ឧស្ម័នឥន្ធនៈត្រូវមានប្រវែងអប្បបរមា ៧,៥ ម៉ែត្រ

៣. ពោងប្រេងឥន្ធនៈកប់ដីត្រូវមានចំណុះមិនលើសពី ៣០ ០០០ លីត្រ

៤. ត្រូវរៀបចំកបំពង់ទទួលប្រេងឥន្ធនៈ

៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ

៦. ចម្ងាយពីទូចាក់ឧស្ម័នឥន្ធនៈទៅកបំពង់ទទួលឧស្ម័នឥន្ធនៈត្រូវមានប្រវែងអប្បបរមា ៦ ម៉ែត្រ

៧. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយ និងគួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ

៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៩. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ

១០. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

១១. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

**ប្រការ៥.-**

ក្រុមហ៊ុនត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល រយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៦២៣.៩៥.អគប្រក.លអអ.......ចុះថ្ងៃទី....២៣............ខែ...មិថុនា......ឆ្នាំ២០.២១..............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៦២៣.៩៥.អគប្រក.លអអ ចុះថ្ងៃទី....២៣.....ខែ...មិថុនា........ឆ្នាំ២០.២១..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានីភ្នំពេញ និងក្រុមហ៊ុនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ.១៤.កើត...ខែបឋមាសាឍ ឆ្នាំឆ្លូវ..ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៣..ខែ.មិថុនា..ឆ្នាំ២០.២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៦៣៣.១៨.អឧប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ០៦៣៣.១៨.អឧប្រក.លអអ.ចុះថ្ងៃទី..២៤.....ខែមិថុនា...ឆ្នាំ ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់លោក ឡាក់ គឹមហេង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ ដេប៉ូតេលា គឹមហេង ឆេងលី គល់ស្ពានកោះធំ ស្ថិតនៅភូមិព្រែកធន់ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល របស់លោក ឡាក់ គឹមហេង (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៣ ម៉ែត្រពីព្រំដីស្ថានីយ ក្នុងទីវាលម្ពូ
៣. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ ម៉ែត្រពីរបងព្រំដីស្ថានីយ ហើយត្រូវមានជញ្ជាំង ឬ របងការពារការប៉ះទង្គិចណាមួយ
៤. បំពង់ខ្យល់ប្រេងឥន្ធនៈមិនត្រូវមានបំពាក់វ៉ាន់បិទ បើក



៩៤

៥. ទូចាក់ប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីរបងស្ថានីយ
៦. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៧. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៨. ត្រូវគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៩. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៦៣៣ រថ.អប្រក.ចអអ......ចុះថ្ងៃទី....២៤...........ខែ..មិថុនា.....ឆ្នាំ២០២១.............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៦៣៣ រថ.អប្រក.ចអអ ចុះថ្ងៃទី...២៤.......ខែ..មិថុនា.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តកណ្តាល និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ...១រោច...ខែបឋមាសាឍឆ្នាំឆ្លូវ..ត្រីស័កព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៤...ខែ.មិថុនា...ឆ្នាំ២០២១
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ សែម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តកណ្តាល
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី